ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខៈ ១០៤/១៣ សជណ អ.ជ.ប.គ.ញ

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣

# របាយការណ៍

## ស្តីពី

## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែកញ្ញា ឆ្នាំ២០១៣
## និងទិសដៅការងារ ខែតុលា ឆ្នាំ២០១៣

(ពីថ្ងៃទី ០១/៩/២០១៣ ដល់ ថ្ងៃទី ៣០/៩/២០១៣)

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តតាមយុទ្ធសាស្ត្រពហុវិស័យ នៃផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដើម្បីរួមចំណែកអនុវត្ត "គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា ។ ជាក់ស្តែង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលបានអនុវត្តនៅក្នុង **ខែកញ្ញា ឆ្នាំ២០១៣** នេះ មានដូចខាងក្រោម :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

តាមរបាយការណ៍របស់អង្គភាពអនុវត្តន៍ច្បាប់ពាក់ព័ន្ធ និងរបាយការណ៍រាជធានី-ខេត្តចំនួន ១៤ គឺ រាជធានីភ្នំពេញ, ខេត្តកណ្តាល, តាកែវ, កំពង់ស្ពឺ, កំពង់ឆ្នាំង, កំពង់ចាម, សៀមរាប, ស្ទឹងត្រែង, រតនគិរី, កំពត, បាត់ដំបង, បន្ទាយមានជ័យ, ពោធិ៍សាត់ និង ខេត្តក្រចេះ ដែលបានរាយការណ៍ពីលទ្ធផលនៃកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន បានបង្ហាញថា សកម្មភាពចរាចរជួញដូរចែកចាយ និងប្រើប្រាស់គ្រឿងញៀន នៅតែបន្តកើតមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលបង្ក្រាបក្នុងខែកញ្ញានេះ បានកត់សំគាល់ឃើញមានបទល្មើសដឹកជញ្ជូនគ្រឿងញៀនឆ្លងដែន ១ ករណី ដែលធ្វើសកម្មភាពដោយជនជាតិរ៉ូមានី បាននាំ **កូកាអ៊ីន** ពីប្រទេសប្រេស៊ីល ឆ្លងកាត់ប្រទេសសិង្ហបុរី ចូលមកកម្ពុជា តាមច្រកអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប ។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone , Fax: (855) 23 721 648, Fax: (855) 23 727 529
E-mail: info@nacd.gov.kh, Website: www.nacd.gov.kh

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### *អំពីការដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន :

- បានណែនាំឱ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ធ្វើបច្ចុប្បន្នភាពទិន្នន័យនៃការអនុវត្ត "គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន" ។
- បានណែនាំឱ្យរៀបចំផ្សព្វផ្សាយជាផ្លូវការនូវទិន្នន័យនៃការប៉ាន់ប្រមាណពីចំនួនអ្នកប្រើបំពានគ្រឿងញៀននៅកម្ពុជា ។
- បានណែនាំឱ្យបន្តការពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃមូលនិធិរបស់អាជ្ញាធរជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- បានណែនាំឱ្យបន្តកម្មវិធីផ្សព្វផ្សាយផែនការជាតិ ៣ ឆ្នាំ (២០១១ -២០១៣) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផ្សព្វផ្សាយរបាយការណ៍ស្តីពី លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆមាសទី១ ឆ្នាំ២០១៣ ។

ទន្ទឹមនេះ ផ្តើមចេញពីគោលការណ៍ដឹកនាំនិងណែនាំរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ក៏ដូចជាផែនការអនុវត្តទិសដៅការងារ ដែលបានដាក់ចេញកាលពី ខែសីហា ឆ្នាំ២០១៣ កន្លងទៅ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តអនុវត្តវិធានការពហុវិស័យទទួលបានលទ្ធផលដូចខាងក្រោម :

### *ក. ការកាត់បន្ថយតម្រូវការគ្រឿងញៀន*

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយមានការចូលរួមយ៉ាងសកម្មពីក្រសួង-ស្ថាប័ន ជាសមាជិក និងក្រសួង-ស្ថាប័នផ្សេងទៀត ជាអាទិ៍ អគ្គិសនីកម្ពុជា បានបន្តយកចិត្តទុកដាក់អនុវត្តការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយតាមកម្មវិធីប្រចាំថ្ងៃ-សប្តាហ៍-ខែ, ការអប់រំតាមសហគមន៍ ទទួលបានលទ្ធផលគួរកត់សំគាល់ **ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី១** ។

**ដោយឡែក អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ** បានចូលរួមជាវាគ្មិន ដើម្បីផ្តល់ការអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងសិក្ខាសាលា ស្តីពីការពង្រឹងការឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍ ក្នុងចំណោមក្រុមប្រឈមខ្ពស់ តាមរយៈកម្មវិធី "ដៃគូសហគមន៍សម្រាប់ប្រជាជនប្រឈមមុខខ្ពស់" របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលរៀបចំនៅខេត្តកោះកុង (ថ្ងៃទី១៣/៩/២០១៣) ។

**ជារួម** សកម្មភាពផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀននៅតាមសហគមន៍ ដែលបានអនុវត្តដោយក្រសួង-ស្ថាប័ន ព្រមទាំងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ចំនួន *៤* គឺ ខេត្តកំពង់ចាម, ស្វាយរៀង, កំពង់ស្ពឺ និង ខេត្តប៉ៃលិន នៅក្នុងខែកញ្ញា ឆ្នាំ២០១៣ នេះ មានមហាជនចូលរួម ***៣៥.៨៣៥ នាក់*** លើ **៧៩.៥៦៩** នាក់ នៃខែសីហា ឆ្នាំ២០១៣ **ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធ ទី១** ។

### *ខ. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន*

ខែកញ្ញាឆ្នាំ២០១៣នេះ មន្ត្រីអនុវត្តន៍ច្បាប់គ្រប់សមាសភាព និងគ្រប់លំដាប់ថ្នាក់ បានបន្តអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀនទទួលបានលទ្ធផលដូចខាងក្រោម :

### ៥.១. ការងារបង្ក្រាបបទល្មើសគ្រឿងញៀន

- **បទល្មើសគ្រឿងញៀន** បង្ក្រាបបាន **៤៩** ករណី លើ ៤៤ ករណី នៃខែសីហា ឆ្នាំ២០១៣
- **ជនសង្ស័យ** ពាក់ព័ន្ធបទល្មើសគ្រឿងញៀន ឃាត់ខ្លួន **៨៩** នាក់ លើ ១០៥ នាក់ នៃខែសីហា ឆ្នាំ២០១៣

ក្នុងចំនួនជនសង្ស័យពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនដែលបានឃាត់ខ្លួន **៨៩** នាក់ ខាងលើ មានប្រុស ៨១ នាក់ ស្រី ៨ នាក់ ក្នុងនោះ ជនជាតិ **ខ្មែរ** ៨៣ នាក់ ( ស្រី ៨ នាក់), **វៀតណាម** ៥ នាក់ ( ប្រុស), រ៉ូមានី ១ នាក់ ( ប្រុស) ។ ត្រូវបានសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ។

- **វត្ថុតាងគ្រឿងញៀនចាប់យក** រួមមាន : មេតំហ្វេតាមីន WY ១៨,៩២ ក្រាម, មេតំហ្វេតាមីនក្រាមម្សៅ Ice ២៥១,៦៦ ក្រាម, កូកាអ៊ីន ៣.៥០០ ក្រាម ។
- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ចាប់យក រួមមាន** : ម៉ូតូ ១៧ គ្រឿង, រថយន្ត ១ គ្រឿង, ប្រាក់កម្ពុជា ១.៦៨០.២០០ រៀល, ប្រាក់អាមេរិក ១៧០ ដុល្លារ **ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី២** ។

**ដោយឡែក ជនសង្ស័យចាប់តាមដីកា** មាន ៦ ដីកា = មនុស្ស ៦ នាក់ ( ប្រុស) ជនជាតិខ្មែរ ។

### ៥.២. ការត្រួតពិនិត្យ និងការគ្រប់គ្រងសារធាតុគីមីផ្សំ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល, ក្រសួងសុខាភិបាល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំ, វត្ថុធាតុដើម និង ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលនៅក្នុងខែ**កញ្ញា** ឆ្នាំ២០១៣ នេះ មានដូចខាងក្រោម :

- សារធាតុគីមី គិតជា គីឡូក្រាម ចំនួន ១.៦៥០.៥៨៥ គ.ក្រ
- វត្ថុធាតុដើម និង ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ចំនួន ៨ គ.ក្រ ១.៥៣៨ ក្រាម និង ១៣០៤ មិល្លីក្រាម

**ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី២**

### ៥.៣. ការងារកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ដែលបញ្ជូនមកពីស្ថាប័នអនុវត្តន៍ច្បាប់នានា នៅក្នុងខែកញ្ញានេះ សរុបបានចំនួន ១១៤ ករណី = ១៣៤ សំណាក ( **សំណាកអវិជ្ជមានសារធាតុញៀន** ៦ សំណាក = ៤ % និង សំណាក **វិជ្ជមានសារធាតុញៀន** ១២៨ សំណាក = ៩៦ %) ក្នុងនោះគឺ ៖

-មេតំហ្វេតាមីនក្រាមម្សៅ ៩០ សំណាក = ៧០ % -មេតំហ្វេតាមីនគ្រាប់ (WY) ៣២ សំណាក = ២៥ %

-ហេរ៉ូអ៊ីន ១ សំណាក = ១ % -កេតាមីន ៥ សំណាក = ៤ %

### ក្រៅពីការងារខាងលើ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានអនុញ្ញាតជាគោលការណ៍ឱ្យថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ១ រូប សហការជាមួយអង្គការ UNOCD ដើម្បីដំណើរការវិភាគរកចម្លើយជាវិជ្ជមានបញ្ជាក់ថា រុក្ខជាតិវល្លិ៍រមៀតមានផ្ទុកសារធាតុអាចផ្សំផលិតជាគ្រឿងញៀនបាន ។

**ដោយឡែក** មន្ទីរប្រឆាំងគ្រឿងញៀននៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានចាត់តាំងមន្ត្រីបង្គោល ១ រូប សម្រាប់ទទួលព័ត៌មានតាមប្រព័ន្ធជូនដំណឹងជាមុនពាក់ព័ន្ធនឹងការនាំចេញសារធាតុគីមី ។

## គ. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់ទីជ្រកជីវៈ និងសមាហរណកម្ម

### គ.១. កម្មវិធីកាត់បន្ថយគ្រោះថ្នាក់

**ការងារក្នុងប្រទេស**

- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ លើកទី២ (២២/៨/២០១៣) លើសេចក្តីព្រាងប្រកាសស្តីពី "លក្ខខណ្ឌការងារ និងវិធានអនាម័យ សន្តិសុខការងារ នៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ផ្នែកសេវាកម្សាន្ត" តាមការអញ្ជើញរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីក្តាប់បានពីបញ្ហាពាក់ព័ន្ធនឹងគ្រឿងញៀន (អ្នកចូលរួម <u>៣០</u> នាក់) ។
- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ១រូប ទៅចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីផែនទីបង្ហាញផ្លូវ សម្រាប់បង្កើតផែនការជាតិអភិវឌ្ឍន៍កុមារ រយៈពេល១០ឆ្នាំ (២០១៥-២០២៥) តាមការអញ្ជើញរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដើម្បីក្តាប់បានពីបញ្ហាពាក់ព័ន្ធនឹងគ្រឿងញៀន (២៨-៣០/៨/២០១៣ មនុស្ស <u>**៦៥**</u> នាក់) ។
- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ១ រូប ចូលរួមកិច្ចប្រជុំផ្តល់យោបល់ និងវាយតម្លៃយេនឌ័រពាក់ព័ន្ធនឹងសេវាកម្ម HIV/AID នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (១១/៩/២០១៣) ដើម្បីក្តាប់បានបញ្ហាពាក់ព័ន្ធនឹងគ្រឿងញៀន ។
- បានចូលរួមសិក្ខាសាលាពង្រឹងការឆ្លើយតបនឹងមេរោគអេដស៍/ជំងឺអេដស៍ ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់តាមរយៈកម្មវិធី "ដៃគូសហគមន៍សម្រាប់ប្រជាជនប្រឈមមុខខ្ពស់" ដែលបានរៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៣ នៅខេត្តស្ទឹងត្រែង (សមាសភាពចូលរួម <u>១០០</u> នាក់) ។

**ការងារក្រៅប្រទេស**

- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋាន និងមន្ត្រីជំនាញ ចំនួន ៣ រូប ទៅចូលរួមសិក្ខាសាលាស្តីពី "ការបង្ការការប្រើបំពានគ្រឿងញៀន ដោយផ្អែកលើសហគមន៍" (ធ្វើនៅប្រទេសហ្វីលីពីន ថ្ងៃទី ០២-០៦/៩/២០១៣) ។

### គ.២. ការព្យាបាល ស្តារនីតិសម្បទា ផ្តល់ទីជ្រកជីវៈ និងសមាហរណកម្ម

**ការងារក្នុងប្រទេស**

- បានជួបពិភាក្សាការងារជាមួយគណៈប្រតិភូថៃ ដែលអញ្ជើញមកធ្វើការវាយតម្លៃសមត្ថភាពការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។ ក្នុងជំនួបពិភាក្សាការងារនៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នាថ្ងៃទី ២៣/៩/២០១៣ (កម្ពុជា មាន ១០ រូប ដឹកនាំដោយឯកឧត្តម លី តឹមឡុង អគ្គលេខាធិការស្តីទី) អគ្គលេខា-ធិការដ្ឋាន បានធ្វើបទបង្ហាញអំពី :
  - ✓ ការបណ្តុះបណ្តាលផ្នែកព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលមន្ទីរពេទ្យ **ថាន់យ៉ារ៉ាក់** បានបណ្តុះបណ្តាលដល់មន្ត្រីកម្ពុជា ។
  - ✓ ស្វែងយល់ពីស្ថានភាពគ្រឿងញៀន រចនាសម្ព័ន្ធនិងប្រព័ន្ធនៃការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅកម្ពុជា ។ ជាមួយនេះដែរ គណៈប្រតិភូក៏បានអញ្ជើញធ្វើទស្សនកិច្ចសិក្សាស្វែងយល់នៅ :

- មជ្ឈមណ្ឌល ឱកាសខ្ញុំ របស់សាលារាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ។
- មជ្ឈមណ្ឌលពិភពនៃក្តីសង្ឃឹម និងមណ្ឌលអប់រំហ្វឹកហ្វឺនស្តារនីតិសម្បទានៃកងរាជអាវុធហត្ថខេត្តបាត់ដំបង កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ ។
- មណ្ឌលស្តារនីតិសម្បទាជីវិតថ្មីភ្នំបាក់ និង មណ្ឌលអប់រំហ្វឹកហ្វឺនស្តារនីតិសម្បទា នៃកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៦ខែកញ្ញា ឆ្នាំ២០១៣ ។

**ការងារក្រៅប្រទេស**

- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋាន និងសម្របសម្រួលជូនមន្ត្រីជំនាញរបស់ក្រសួងសមាជិក និងមន្ត្រីគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន រាជធានី-ខេត្ត ទៅទទួលវគ្គបណ្តុះបណ្តាលគំរូលើកទី៥ ស្តីពីការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន (ប្រទេសថៃ ថ្ងៃទី០៩-២០/៩/២០១៣) ។

## *ឃ. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់*

**ការងារក្នុងប្រទេស**

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចូលរួមសិក្ខាសាលាស្តីពី ការប្រយុទ្ធប្រឆាំងទៅនឹងការរត់ពន្ធឆ្លងកាត់ព្រំដែនសម្រាប់មន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន (BLO) ដែលបម្រើការនៅតាមបណ្តោយព្រំដែន កម្ពុជា-ថៃ ដែលរួមមាន ការិយាល័យទំនាក់ទំនងព្រំដែន ចាំយាម (ខេត្តកោះកុង), ព្រំ (ខេត្តប៉ៃលិន), ដូង (ខេត្តបាត់ដំបង), និងប៉ោយប៉ែត (ខេត្តបន្ទាយមានជ័យ) កាលពី ថ្ងៃទី២០-២៣/៨/២០១៣ លើមុខជំនាញដូចជា ការសួរចម្លើយ, ការស៊ើបអង្កេត, ការកសាងសំណុំរឿងជនល្មើស, ការឆែកឆេររថយន្ត, ការរក្សាវត្ថុតាងនិងកន្លែងកើតហេតុ, ការទប់ស្កាត់ការជួញដូរគ្រឿងញៀន សត្វព្រៃ និង សារធាតុដែលប៉ះពាល់ដល់ស្រទាប់អូហ្សូន, ការប្រឆាំង ទប់ស្កាត់ការជួញដូរទេសន្តរប្រវេសន៍ និងការត្រួតពិនិត្យលិខិតឆ្លងដែន ។

**ការងារក្រៅប្រទេស**

- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ចំនួន ២ រូប ទៅចូលរួមសិក្ខាសាលា ស្តីពីកម្មវិធី Global Smart ប្រចាំតំបន់អាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍ (២៨-២៩/៨/២០១៣) នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី ក្នុងគោលបំណង :
  ១. ធ្វើបច្ចុប្បន្នភាពលើភាពជាដៃគូ ស្តីពីការអនុវត្តកម្មវិធី Global Smart ។
  ២. ធ្វើការចែករំលែកព័ត៌មានស្តីពីគ្រឿងញៀន ពិសេសគ្រឿងញៀនប្រភេទ ATS និងសារធាតុប៉ះពាល់សរសៃប្រសាទ និងការទទួលខុសត្រូវរបស់រដ្ឋភាគី ដែលជាសមាជិក ។
  ៣. ពិភាក្សាពីផែនការសម្រាប់អនាគត ពិសេសស្តីពីការចែករំលែកទិន្នន័យព័ត៌មានស្តីពីការប្រើបំពានគ្រឿងញៀនសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក (DAINAP) ។
- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ១រូបទៅចូលរួមសិក្ខាសាលា ស្តីពីការរៀបចំកែសម្រួលកម្មវិធីបណ្តុះបណ្តាលរួមគ្នាអំពីកិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែន សម្រាប់មន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន (BLO) នៃប្រទេស

ក្នុងមហាអនុតំបន់ទន្លេមេគង្គ (កម្ពុជា ថៃ ឡាវ វៀតណាម មីយ៉ាន់ម៉ា និង ចិន) កាលពីថ្ងៃទី ២៦-២៧/៨/២០១៣ ដើម្បីពិភាក្សានិងរៀបចំយន្តការនៃការបណ្តុះបណ្តាលឱ្យមានលក្ខណៈសកលជាងមុន ដែលអាចឱ្យមន្ត្រីអនុវត្តន៍ច្បាប់នៅក្នុងប្រទេសទាំង៦ខាងលើ អាចយកទៅអនុវត្តនៅក្នុងកិច្ចប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួនបាន ។

## ខ. កិច្ចសហប្រតិបត្តិការអន្តរជាតិ

ខែកញ្ញាឆ្នាំ២០១៣ នេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបន្តកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជិតខាង ប្រទេសក្នុង អនុតំបន់ តំបន់ និង អន្តរជាតិ មានដូចខាងក្រោម :

**ការងារក្នុងប្រទេស**

- បានចូលរួមផ្តល់យោបល់និងយល់ព្រម លើសេចក្តីព្រាងនីតិវិធីកិច្ចសហប្រតិបត្តិការ សម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-ថៃ ។
- បានរៀបចំទទួលគណៈប្រតិភូថៃ ដែលអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី ២៣-២៧ ខែកញ្ញា ឆ្នាំ២០១៣ ។

**ការងារក្រៅប្រទេស**

- ថ្នាក់ដឹកនាំជាន់ខ្ពស់នៃអាជ្ញាធរជាតិ បានអញ្ជើញចូលរួមកិច្ចប្រជុំពិសេសថ្នាក់រដ្ឋមន្ត្រីអាស៊ាន ស្តីពីបញ្ហាគ្រឿងញៀន កាលពីថ្ងៃទី០២-០៣/៩/២០១៣ នៅប្រទេសប្រ៊ុយណេ ។
- បានបញ្ជូនគណៈប្រតិភូអន្តរក្រសួងរបស់ អ.ជ.ប.គ.ញ ចំនួន ១០ រូប ទៅទស្សនកិច្ចសិក្សាស្វែងយល់ពីការងារត្រួតពិនិត្យគ្រឿងញៀន នៅខេត្តយូណាន ប្រទេសចិន (ពីថ្ងៃទី០៩-១៣/៩/២០១៣) ។
- បានបញ្ជូនថ្នាក់ដឹកនាំនាយដ្ឋានជំនាញ និងសម្របសម្រួលជូនមន្ត្រីអនុវត្តន៍ច្បាប់នៃស្ថាប័នពាក់ព័ន្ធ ទៅចូលរួមទស្សនកិច្ចសិក្សាស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមអាកាសយានដ្ឋានអន្តរជាតិ (ធ្វើនៅប្រទេសហ្វីលីពីន ថ្ងៃទី ២៣-២៧/៩/២០១៣) ។
- បានបញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ១រូប ទៅចូលរួមកិច្ចប្រជុំក្រោមឈ្មោះថា កិច្ចពិភាក្សាអ្នកស្វែងរកផ្លូវ ដែលរៀបចំដោយកម្មវិធីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក សំដៅស្វែងរកដំណោះស្រាយស្តីពីការពង្រឹងសេដ្ឋកិច្ច និងការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែនក្នុងតំបន់ (ធ្វើនៅក្រុងបាងកក ប្រទេសថៃ ថ្ងៃទី ២៣-២៥/៩/២០១៣) ។
- បានបញ្ជូនប្រតិភូ របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ទៅចូលរួមក្នុងកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់អាស៊ាន ស្តីពីបញ្ហាគ្រឿងញៀន (ASOD) លើកទី៣៤ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន កាលពីថ្ងៃទី២៤-២៧ ខែកញ្ញា ឆ្នាំ២០១៣ នៅសហភាពមីយ៉ាន់ម៉ា ។ អង្គប្រជុំបានធ្វើបទអន្តរាគមន៍ និងបទបង្ហាញពីស្ថានភាពនិង លទ្ធផលនៃកិច្ចប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនក្នុងឆ្នាំកន្លងមក ពិសេសពាក់ព័ន្ធនឹងការអនុវត្តអនុសាសន៍របស់ថ្នាក់ដឹកនាំកំពូលអាស៊ាន ដែលបានធ្វើឡើងតាមរយៈកិច្ចប្រជុំពិសេសថ្នាក់រដ្ឋមន្ត្រីអាស៊ាន លើកទី១ ។ កិច្ចប្រជុំបានបែងចែកជា ៥ ក្រុមការងារដើម្បីពិនិត្យ ពិភាក្សាលើ ការងារអប់រំបង្ការ, ការងារអនុវត្តច្បាប់, ការងារព្យាបាល និងស្តារនីតិសម្បទា, ការងារសិក្សាស្រាវជ្រាវ និង ការងារអភិវឌ្ឍន៍ដំណាំជំនួស ។

**ដោយឡែក**

**-ខេត្តមណ្ឌលគិរី** ថ្ងៃទី៣០/៨/២០១៣ ស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី និងស្នងការដ្ឋាននគរបាលខេត្តដាក់ឡាក់ (វៀតណាម) បានបើកកិច្ចប្រជុំស្តីពី កិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែន ឆមាសទី១ ឆ្នាំ២០១៣ និងទិសដៅ ឆមាសទី២ ឆ្នាំ២០១៣ (ធ្វើនៅស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី) ដែលមានសមាសភាពចូលរួម(ខាងភាគីកម្ពុជាសរុប **២៥** រូប) ។ ភាគីទាំង២ បានឯកភាពនិងចុះហត្ថលេខាបន្តកិច្ចសហប្រតិបត្តិការលើ៥ចំណុច ដែលក្នុងនោះមានចែងអំពីបទល្មើសគ្រឿងញៀនឆ្លងកាត់ព្រំដែនផងដែរ ។

**-ខេត្តបន្ទាយមានជ័យ** ថ្ងៃទី០៦/៩/២០១៣ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត បានជួបពិភាក្សាការងារ ជាមួយអាជ្ញាធរខេត្តស្រះកែវ (ថៃ) ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀននៅបន្ទាត់ព្រំដែន កម្ពុជា-ថៃ (ធ្វើនៅស្រុកអារញ្ញ ខេត្តស្រះកែវ សមាសភាពខាងភាគីកម្ពុជា មាន **២៥** រូប) ។

**-ខេត្តឧត្តរមានជ័យ** ថ្ងៃទី១៧/៩/២០១៣ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត (ដឹកនាំដោយឯកឧត្តម ស ថាវី អភិបាល នៃគណៈអភិបាលខេត្ត ) បានចូលរួមក្នុងកិច្ចប្រជុំការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។ កិច្ចប្រជុំនេះ ធ្វើនៅ ច្រកជាំ កម្ពុជា (ខាងកម្ពុជា មាន **២៥** រូប) និងច្រកជាំសាងាំ (ថៃ) ដើម្បីផ្លាស់ប្តូរសភាពការណ៍, បទពិសោធន៍ទៅវិញទៅមក និងដាក់ចេញនូវវិធានការសម្រាប់ទប់ស្កាត់បទល្មើសគ្រឿងញៀនឆ្លងដែនឱ្យកាន់តែមានប្រសិទ្ធភាព ។

***ការងារផ្សេងៗ :***

- បានប្រជុំក្រុមការងាររៀបចំសេចក្តីព្រាងបទដ្ឋានគតិយុត្ត ដែលទាក់ទងនឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដើម្បីបន្តការពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិរបស់អាជ្ញាធរជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន (១១/៩/២០១៣) ។
- បានចុះទៅខេត្តស្ទឹងត្រែង ដើម្បីផ្សព្វផ្សាយរបាយការណ៍ស្តីពី លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆមាសទី១ ឆ្នាំ២០១៣ និងទិសដៅការងារ ឆមាសទី២ ឆ្នាំ២០១៣ (ថ្ងៃទី២០/៩/២០១៣) អ្នកចូលរួម **១២៧** រូប ។
- បានរៀបចំកិច្ចប្រជុំពិភាក្សាការងារជាមួយដៃគូពាក់ព័ន្ធ រៀបចំពិធីផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៣-២០១៥ កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៣ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។

## III. ផែនការសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែតុលា ឆ្នាំ២០១៣

ដើម្បីធានានិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តអនុវត្តទិសដៅសកម្មភាពការងារមួយចំនួនដូចខាងក្រោម :

### ១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

១.១. ស្នើសុំទៅគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តស្ទឹងត្រែង ដើម្បីផ្តល់កិច្ចសម្ភាសន៍តាមកម្មវិធី សភាអ៊ិនធើណែតនៃស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី អំពីសកម្មភាពនិងលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន នៅក្នុងភូមិសាស្ត្រខេត្តស្ទឹងត្រែង (ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣) ។

១.២. ចូលរួមក្នុងពិធីបិទ កម្មវិធីពិសេសមហោស្រពប្រឡង តន្ត្រី ចម្រៀងសម័យ ថ្នាក់ជាតិ ឆ្នាំ២០១៣ (ថ្ងៃទី២៩/៩/

២០១៣) នៅអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ។

១.៣. បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត វិស័យឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀនទៅក្នុងការប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្ម នៅតាមរាជធានី-ខេត្ត និងនៅតាមវិទ្យាល័យក្នុងរាជធានីភ្នំពេញ ។

១.៤. បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករ តន្ត្រីករ ដើម្បីជំរុញកម្មវិធីផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងឯកជន ។

## ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

២.១. សហការសម្របសម្រួលជាមួយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ដើម្បីរៀបចំសេចក្តីព្រាងប្រកាសស្តីពីការដាក់ស្លាកសញ្ញាសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម ។

២.២. សហការជាមួយអង្គការ UNODC ដើម្បីដំណើរការវិភាគឱ្យបានច្បាស់លាស់ពីរុក្ខជាតិវល្លិ៍រមៀត ដែលសង្ស័យថាមានផ្ទុកសារធាតុផ្សំសម្រាប់ផលិតគ្រឿងញៀនខុសច្បាប់ ។

## ៣. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម

៣.១. រៀបចំគម្រោងសម្រាប់ការបណ្តុះបណ្តាលពាក់ព័ន្ធផ្នែកព្យាបាល និង ផ្នែកស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងគម្រោងតម្រូវការសម្ភារៈ ឱសថ ដែលត្រូវផ្តល់ដោយភាគីវៀតណាម ។

៣.២. ត្រៀមបញ្ជូនក្រុមការងារអន្តរក្រសួង ទៅប្រទេសវៀតណាម ដើម្បីពិភាក្សាពីជំនួយរបស់ភាគីវៀតណាម ពាក់ព័ន្ធនឹងការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

៣.៣. សហការជាមួយក្រសួងសុខាភិបាល ដើម្បីរៀបចំឯកសារដែលពាក់ព័ន្ធនឹងការបង្ការ ការថែទាំ និងព្យាបាលបន្ត និង ស្តារនីតិសម្បទាចិត្ត-សង្គម ចំពោះអ្នកប្រើប្រាស់គ្រឿងញៀន និងអ្នកចាក់គ្រឿងញៀន ។

៣.៤. រៀបចំយន្តការ និងបែបបទសម្រាប់ការអនុវត្តកម្មវិធី ម្ជុល/សឺរ៉ាំង តាមប្រព័ន្ធសុខាភិបាល ។

៣.៥. បន្តការផ្តល់សេវាថែទាំ ព្យាបាល និងផ្តល់របបឧបត្ថម្ភដល់អ្នកញៀនគ្រឿងញៀន ដែលកំពុងសម្រាកព្យាបាលនៅតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ ។

៣.៦. បន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងសុខាភិបាល ជំរុញការអនុវត្តកម្មវិធី មេតាដូន នៅមន្ទីរពេទ្យមិត្ត-ភាព ខ្មែរ-សូវៀត ។

៣.៧. ជំរុញការរៀបចំឯកសារគោលសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ ក្នុងការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ។

៣.៨. ចូលរួមវគ្គបណ្តុះបណ្តាលបំប៉នស្តីពី ការព្យាបាល ការថែទាំ និងផ្តល់ប្រឹក្សាអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ ដល់មន្ត្រីសុខាភិបាលខេត្តបាត់ដំបង និង ខេត្តបន្ទាយមានជ័យ (៣០/៩-០២/១០/២០១៣) ។

៣.៩. សហការជាមួយការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្ម (UNODC) រៀបចំផ្សព្វផ្សាយកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ជាមូលដ្ឋាន ឆ្នាំ២០១២ របស់ខេត្តបន្ទាយមានជ័យ (CBTx) ។

## ៤. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

៤.១. បន្តកិច្ចសហការជាមួយអង្គការFHI360 ក្នុងការពង្រឹងសមត្ថភាពមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន របស់អគ្គ-លេខាធិការដ្ឋាន អ.ជ.ប.គ.៣ ( ខែតុលា ២០១៣) ។

៤.២. រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីនគរបាល នៅសាលាបណ្ឌិត្យសភានគរបាលកម្ពុជា និងសាលានគរបាលភូមិភាគទាំង ៦ ( ខែតុលា ២០១៣) ។

៤.៣. រៀបចំក្រុមបាឋកថាសម្រាប់ឧទ្ទេសនាមឯកសារនៅសាលាបណ្ឌិត្យសភានគរបាលកម្ពុជា( ខែតុលា/២០១៣) ។

៤.៤. ត្រៀមសហការជាមួយFHI360 និងសាលានគរបាល ដើម្បីចុះអភិបាលកិច្ច អំពីការបង្រៀននៅតាមសាលាបណ្ឌិត្យសភានគរបាលកម្ពុជា និងសាលានគរបាលភូមិភាគ ។

៤.៥. រៀបចំទទួលសម្ភារៈរបស់មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀនពីអង្គការFHI360 ( ខែតុលា ២០១៣) ។

៤.៦. រៀបចំវគ្គបណ្តុះបណ្តាល ដើម្បីត្រួតពិនិត្យនិងវាយតម្លៃ មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ( ខែតុលា ២០១៣) ។

៤.៧. បន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងការពារជាតិ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដល់កងយោធពលខេមរភូមិន្ទ ពិសេសកងទ័ពឈរជើងនៅតាមខ្សែបន្ទាត់ព្រំដែននៃបណ្តាខេត្តនៅភាគឦសាន ។

៤.៨. បន្តរៀបចំវគ្គបណ្តុះបណ្តាល ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមប្រព័ន្ធកុំព្យូទ័រ ( កម្មវិធី CBT) ។

៤.៩. សហការជាមួយអង្គការ FHI360 រៀបចំកិច្ចប្រជុំតុមូល ដើម្បីពិភាក្សាបន្តលើកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ។

៤.១០. បន្តបញ្ជ្រាបកម្មវិធីការកាត់បន្ថយគ្រោះថ្នាក់ ទៅក្នុងកម្មវិធីសិក្សារបស់សាលាបណ្ឌិត្យសភានគរបាលកម្ពុជា ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

៥.១. ត្រៀមចូលរួមកិច្ចប្រជុំ លើកទី៣៧ នៃថ្នាក់ដឹកនាំទីភ្នាក់ងារប្រតិបត្តិច្បាប់ជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននៃអាស៊ីនិងប៉ាស៊ីហ្វិក (HONLEA) ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២១-២៤ខែតុលាឆ្នាំ២០១៣ នៅក្រុងបាងកក ប្រទេសថៃ ។

៥.២. ត្រៀមចាត់បញ្ជូនមន្ត្រីជំនាញទៅចូលរួមវគ្គបណ្តុះបណ្តាល "អាស៊ាន+៣ ស្តីពីការងារអនុវត្តច្បាប់គ្រឿងញៀនសំយោគនិងសារធាតុគីមីផ្សំ" នៅក្រុងបាងកក និងខេត្តឈុនបុរី ប្រទេសថៃ (២១/១០-០១/១១/២០១៣) ។

៥.៣. រៀបចំពិធីទទួលសម្ភារៈ ដែលឧបត្ថម្ភដោយគណៈកម្មការជាតិត្រួតពិនិត្យគ្រឿងញៀនចិន (NNCC) តាមរយៈអង្គការ UNODC និង សម្ភារៈគម្រោង PATROL ។

៥.៤. ត្រៀមរៀបចំគណៈប្រតិភូ ទៅចូលរួមកិច្ចប្រជុំទ្វេភាគី កម្ពុជា-ចិន លើកទី៤ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន នៅប្រទេសចិន ( ០៤-០៨/១១/២០១៣) ។

៥.៥. ត្រៀមចាត់បញ្ជូនមន្ត្រីជាន់ខ្ពស់ ទៅចូលរួមសិក្ខាសាលាបង្កើតគម្រោង H15 ថ្មី ដើម្បីពង្រឹងយន្តការក្នុងការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន (MOU) ។

៥.៦. ត្រៀមរៀបចំកិច្ចប្រជុំ ត្រីភាគី ទ្វេភាគី ថ្នាក់រដ្ឋមន្ត្រី ប្រទេសកម្ពុជា វៀតណាម ឡាវ (ធ្វើនៅកម្ពុជា) ។

៥.៧. ត្រៀមរៀបចំផ្សព្វផ្សាយខ្លឹមសារនៃកិច្ចប្រជុំ អាស៊ាន ស្តីពីបញ្ហាគ្រឿងញៀន (ASOD) ។

ក្រៅពីទិសដៅការងារខាងលើ អគ្គលេខាធិការដ្ឋាននឹងបន្តអនុវត្តការងារមួយចំនួនទៀត ដើម្បីបំពេញឱ្យយុទ្ធសាស្ត្រជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានដូចជា :

- រៀបចំដំណើរការផ្សព្វផ្សាយជាផ្លូវការនូវទិន្នន័យនៃការប៉ាន់ប្រមាណពីចំនួនអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា ។
- បន្តការពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិរបស់អាជ្ញាធរជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- ធ្វើបច្ចុប្បន្នភាព គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ឆ្នាំ២០១៣ ។
- បន្តធ្វើបច្ចុប្បន្នភាព លើបញ្ជីសារពើភណ្ឌសម្ភារៈគម្រោង CMBF14 ។

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក យូ-ស៊ុនឡុង

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ឯកឧត្តម កៅ ខុនជាភិ អនុប្រធាន អ.ជ.ប.គ.ញ

-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន

"ដើម្បីជូនជ្រាប"

-ក្រសួង សមាជិក អ.ជ.ប.គ.ញ

-ក្រសួងផែនការ

-អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត

-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីមុខការ"

-ឯកសារ